**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៥៤១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការកាត់ដីសរុបទំហំ ៦៧៨,២៦ ហិកតា នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ក្នុងនោះ កាត់ចេញពី (១) កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ ២០០២ (២) កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន សុវណ្ណាវិចឡាន់ (៣) កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហ្វូនណាផ្លេនថេលសិន ខេមបូឌា លីមីធីត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៧៦គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល



www.pheakdeylaw.com

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៦២អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ១៧អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្ដីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- បានឃើញលិខិតលេខ ៤៧៦អបខ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១**: ត្រូវបានកាត់ដីសរុបទំហំ ៦៧៨,២៦ហិកតា ក្នុងនោះ (១) ដីទំហំ ៥៤៤,៧១ហិកតា កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ (២) ដីទំហំ ១៣៣,៥៥ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន សុវណ្ណវិវឌ្ឍន៍ (៣) ដីទំហំ ៧,១៤ហិកតា កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហ្វូនណា ផ្លេនថេលសិន ខេមបូឌា លីមីធីត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មដីទំហំ ៦៦៤,៩៩ហិកតា ជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្ដែង និងដីទំហំ ១៣,២៧ហិកតា រក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅភូមិដក់ពរ ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ តាមប្រព័ន្ធកូអរដោណេ Projection UTM Zone 48N Datum WGS 84 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ ។

**មាត្រា ២**: ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីរបស់រដ្ឋដូចមានចែងក្នុងមាត្រា ១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋចំនួន ២៧៦គ្រួសារ ដែលបានកាន់កាប់ ប្រើប្រាស់ និងដាំដុះជាក់ស្ដែង នៅភូមិដក់ពរ ឃុំក្រាំងដីវ៉ាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។



www.pheakdeylaw.com

**មាត្រា ៣**: ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្តែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ស្ពឺ ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្របដើម្បីរក្សាទុកបម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៤**: បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥**: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

កន្លែងទទួល៖

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា ធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា អភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*



www.pheakdeylaw.com

ឧបសម្ព័ន្ធ ៥ នៃអនុក្រឹត្យលេខ..........................................ចុះថ្ងៃទី.........ខែ..........ឆ្នាំ២០១៣ ស្តីពីការកាត់ឆ្វៀលដីសរុបទំហំ ១៤០,៦៩ ហិកតា ចេញពីផែនទីគម្របព្រៃឈើឆ្នាំ២០០២ ក្រុមហ៊ុនសុខណ្ណចិត្រឡាន់ . ក្រុមហ៊ុនហ្វដ្ឋណា ផ្លេនថេលសិន ខេមបូឌា លីមីធីត ដែលក្នុងនោះត្រូវបានធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ឆ្វៀលដីទំហំ ១៣៩,១២ ហិកតា ដើម្បីធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ដែលបានកាន់កាប់ ប្រើប្រាស់ និងជាំដុះជាក់ស្តែង ចំនួន ៤៤ គ្រួសារ និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ ទំហំ ១,៥៨ ហិកតា នៅភូមិជក់ពារ ឃុំក្រាំងជីវាំយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ



ឧបសម្ព័ន្ធ ១ នៃអនុក្រឹត្យលេខ.៥៤១..អនក្រ..បក.........................ចុះថ្ងៃទី.០៥...ខែ..ធ្នូ..ឆ្នាំ២០១៣ ស្តីពីការកាត់ដីទំហំ ៦៧៨,២៦ហិកតា នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ក្នុងនោះកាត់ចេញពី (១)កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ (២)កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនសុខណ្ណចិតឡូន៍ (៣)កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនហ្វូដុនណា ផ្លេនថេលសិន ខេមបូឌា លីមីធីត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៧៦គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ



ឧបសម្ព័ន្ធ ២ នៃអនុក្រឹត្យលេខ ៥៤១ អនក្រ.បក ............................. ចុះថ្ងៃទី ១៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកាត់ដីទំហំ ៦៧៨.២៦ហិកតា នៅស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ក្នុងនោះកាត់ចេញពី (១)កាត់ចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ (២)កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនសុទណ្ណទិចឡូន៍ (៣)កាត់ចេញពីដីសម្បទានសេដ្ឋកិច្ចរបស់ក្រុមហ៊ុនហ្វជុនណា ផ្លេនថេសិន ខេមបូឌា លីមីធីត និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋ ២៧៦គ្រួសារ និងរក្សាទុកមួយចំណែកជាដីសាធារណៈរបស់រដ្ឋ




តារាងកូអរដោនេ

| ID | X | Y | ID | X | Y | ID | X | Y |
|---|---|---|---|---|---|---|---|---|
| តំបន់ I | | | 61 | 415787 | 1268624 | 121 | 415826 | 1268470 |
| 1 | 414872 | 1269177 | 62 | 415782 | 1268469 | 122 | 415826 | 1268496 |
| 2 | 414977 | 1269186 | 63 | 415760 | 1268510 | 123 | 415834 | 1268521 |
| 3 | 415047 | 1269200 | 64 | 415717 | 1268429 | 124 | 415837 | 1268547 |
| 4 | 415114 | 1269225 | 65 | 415744 | 1268394 | តំបន់ III | | |
| 5 | 415139 | 1269190 | 66 | 415715 | 1268332 | 125 | 415876 | 1268084 |
| 6 | 415361 | 1269276 | 67 | 415662 | 1268332 | 126 | 415916 | 1268046 |
| 7 | 415413 | 1269302 | 68 | 415568 | 1268367 | 127 | 415912 | 1267981 |
| 8 | 415480 | 1269288 | 69 | 415526 | 1268270 | 128 | 415863 | 1267987 |
| 9 | 415613 | 1269296 | 70 | 415463 | 1268248 | តំបន់ IV | | |
| 10 | 415621 | 1269289 | 71 | 415446 | 1268260 | 129 | 417767 | 1270577 |
| 11 | 415623 | 1269290 | 72 | 415472 | 1268323 | 130 | 417801 | 1270527 |
| 12 | 415668 | 1269306 | 73 | 415482 | 1268366 | 131 | 417801 | 1270626 |
| 13 | 415678 | 1269310 | 74 | 415396 | 1268386 | 132 | 417806 | 1270489 |
| 14 | 415644 | 1269333 | 75 | 415206 | 1268306 | 133 | 417811 | 1270434 |
| 15 | 415646 | 1269334 | 76 | 415142 | 1268301 | 134 | 417811 | 1270432 |
| 16 | 415662 | 1269338 | 77 | 415079 | 1268297 | 135 | 417809 | 1270372 |
| 17 | 415689 | 1269371 | 78 | 415013 | 1268294 | 136 | 417806 | 1270327 |
| 18 | 415689 | 1269371 | 79 | 414993 | 1268413 | 137 | 417801 | 1270276 |
| 19 | 415740 | 1269380 | 80 | 415065 | 1268408 | 138 | 417786 | 1270256 |
| 20 | 415741 | 1269380 | 81 | 415116 | 1268409 | 139 | 417766 | 1270231 |
| 21 | 415741 | 1269380 | 82 | 415171 | 1268419 | 140 | 417737 | 1270187 |
| 22 | 415742 | 1269381 | 83 | 415323 | 1268492 | 141 | 417680 | 1270190 |
| 23 | 415771 | 1269397 | 84 | 415371 | 1268525 | 142 | 417623 | 1270162 |
| 24 | 415773 | 1269408 | 85 | 415411 | 1268667 | 143 | 417574 | 1270117 |
| 25 | 415776 | 1269434 | 86 | 415413 | 1268730 | 144 | 417524 | 1270079 |
| 26 | 415790 | 1269747 | 87 | 415433 | 1268727 | 145 | 417443 | 1270060 |
| 27 | 415818 | 1269863 | 88 | 415424 | 1268747 | 146 | 417396 | 1270030 |
| 28 | 415817 | 1269880 | 89 | 415332 | 1268716 | 147 | 417369 | 1270028 |
| 29 | 415930 | 1269896 | 90 | 415260 | 1268728 | 148 | 417309 | 1270017 |
| 30 | 415934 | 1269882 | 91 | 415187 | 1268723 | 149 | 417201 | 1270010 |
| 31 | 415946 | 1269874 | 92 | 415066 | 1268720 | 150 | 417161 | 1270000 |
| 32 | 416024 | 1269793 | 93 | 414987 | 1268718 | 151 | 417036 | 1269973 |
| 33 | 416080 | 1269698 | 94 | 414906 | 1268721 | 152 | 416931 | 1269928 |
| 34 | 416090 | 1269687 | 95 | 414897 | 1268818 | 153 | 416900 | 1269908 |
| 35 | 416097 | 1269607 | 96 | 414886 | 1268930 | 154 | 416807 | 1269716 |
| 36 | 416089 | 1269496 | 97 | 414886 | 1269047 | 155 | 416836 | 1269840 |
| 37 | 416186 | 1269324 | 98 | 414884 | 1269057 | 156 | 416818 | 1269933 |
| 38 | 416188 | 1269321 | តំបន់ II | | | 157 | 416776 | 1270067 |
| 39 | 416244 | 1269288 | 99 | 415943 | 1268671 | 158 | 416889 | 1270112 |
| 40 | 416247 | 1269298 | 100 | 415957 | 1268681 | 159 | 416984 | 1270140 |
| 41 | 416317 | 1269340 | 101 | 415955 | 1268632 | 160 | 417162 | 1270157 |
| 42 | 416317 | 1269386 | 102 | 415964 | 1268626 | 161 | 417197 | 1270170 |
| 43 | 416403 | 1269380 | 103 | 415963 | 1268612 | 162 | 417316 | 1270167 |
| 44 | 416414 | 1269280 | 104 | 415962 | 1268601 | 163 | 417368 | 1270167 |
| 45 | 416413 | 1269240 | 105 | 415961 | 1268481 | 164 | 417381 | 1270171 |
| 46 | 416422 | 1269290 | 106 | 415980 | 1268476 | 165 | 417396 | 1270179 |
| 47 | 416310 | 1269220 | 107 | 415980 | 1268472 | 166 | 417427 | 1270194 |
| 48 | 416327 | 1269086 | 108 | 415948 | 1268460 | 167 | 417470 | 1270228 |
| 49 | 416207 | 1269022 | 109 | 415946 | 1268440 | 168 | 417498 | 1270262 |
| 50 | 416209 | 1269021 | 110 | 415932 | 1268320 | 169 | 417582 | 1270338 |
| 51 | 416140 | 1268986 | 111 | 415930 | 1268301 | 170 | 417636 | 1270469 |
| 52 | 416131 | 1268982 | 112 | 415930 | 1268292 | 171 | 417699 | 1270528 |
| 53 | 416123 | 1268990 | 113 | 415928 | 1268216 | តំបន់ V | | |
| 54 | 416117 | 1268996 | 114 | 415928 | 1268216 | 172 | 417143 | 1270713 |
| 55 | 416093 | 1269030 | 115 | 415916 | 1268160 | 173 | 417372 | 1270741 |
| 56 | 415968 | 1268918 | 116 | 415916 | 1268149 | 174 | 417382 | 1270688 |
| 57 | 415913 | 1268872 | 117 | 415814 | 1268156 | 175 | 417343 | 1270633 |
| 58 | 415906 | 1268806 | 118 | 415820 | 1268247 | 176 | 417269 | 1270602 |
| 59 | 415867 | 1268748 | 119 | 415826 | 1268314 | 177 | 417145 | 1270576 |
| 60 | 415830 | 1268718 | 120 | 415815 | 1268321 | | | |

www.pheakdeylaw.com